# ការធ្វើពិពិធកម្មកសិកម្មក្នុងចម្ការកៅស៊ូ

## ១. លក្ខណៈទូទៅ

ពិពិធកម្មកសិកម្មក្នុងចម្ការកៅស៊ូគឺជាការធ្វើរបរកសិកម្មច្រើនប្រភេទនៅលើផ្ទៃដីតែមួយ ជាមួយនឹងដំណាំកៅស៊ូដូចជាដំណាំចន្លោះរង (ដំណាំរដូវ ដំណាំឈើហូបផ្លែ) ដំណាំគម្របដី និងការចិញ្ចឹមសត្វជាដើម។ តាមបទដ្ឋានបច្ចេកទេស ការដាំដុះដំណាំកៅស៊ូមានរយៈពេល៦ ទៅ ៧ឆ្នាំ ទើបប្រមូលផលបានដែលជាពេលវេលាមួយកសិករត្រូវការចំណាយថវិកាច្រើនដើម្បីធ្វើការថែទាំ (ការដាក់ជី ការសម្អាតស្មៅ និងការការពារជំងឺ) ជាដើម។ ម៉្យាងវិញទៀត ស្របពេលតម្លៃកៅស៊ូមានការធ្លាក់ចុះចាប់ពីឆ្នាំ២០១២មក នាំឲ្យកសិករទទួលបានប្រាក់ចំណូលទាបពីការលក់ជ័រកៅស៊ូ។ ដូច្នេះ កសិករកៅស៊ូគ្រួសារត្រូវធ្វើពិពិធកម្មកសិកម្មនៅក្នុងចម្ការកៅស៊ូដើម្បីទទួលបានប្រាក់ចំណូលបន្ថែមទៀត ក្នុងអំឡុងពេលកៅស៊ូមិនទាន់ផ្តល់ផល។

ការធ្វើពិពិធកម្មកសិកម្មក្នុងចម្ការកៅស៊ូផ្តល់សារៈប្រយោជន៍ជាច្រើនដូចជា៖

- ទប់ស្កាត់ការលូតលាស់រុក្ខជាតិចង្រៃ
- ធ្វើឲ្យប្រសើរឡើងនូវលក្ខណៈរបស់ដី និងផ្តល់សារធាតុចិញ្ចឹមក្នុងដី
- កាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្ម
- កាត់បន្ថយការហូរច្រោះដី
- ប្រាក់ចំណូលបន្ថែមដល់កសិករ។

### ក. ដំណាំចន្លោះរង (Intercrop)

ប្រភេទដំណាំចន្លោះរងដែលគេនិយមដាំដុះនៅក្នុងចម្ការកៅស៊ូចាប់ពីកៅស៊ូអាយុ ១-៣ ឆ្នាំ មានដូចជា៖ សណ្តែកដី សណ្តែកបាយ សណ្តែកសៀង ខ្ញី ម្នាស់ និងដំណាំប្រចាំរដូវផ្សេងៗទៀត។ ក្រៅពីដំណាំរដូវទាំងនោះ គេក៏អាចដាំដុះដំណាំរយៈពេលវែងដូចជា៖ សាវម៉ាវ ចេក កាហ្វេ ក្រូចខ្វិច ធូរេន និងដូងតឿផងដែរ។ ប៉ុន្តែ ដំណាំចន្លោះរងរយៈពេលវែងទាំងនោះ អាចអនុវត្តបានតែក្នុងករណីដែលចម្ការកៅស៊ូដាំជាជួរភ្លោះតែប៉ុណ្ណោះ។







*រូបភាពទី១៖ ការដាំដំណាំចន្លោះរងកៅស៊ូ*

**ខ. ដំណាំគម្របដី (Cover crops)**

ក្រៅពីដំណាំចន្លោះរងដូចបានរៀបរាប់ខាងលើ គេក៏អាចដាំដំណាំគម្របដីនៅចន្លោះរងកៅស៊ូបានដែរ។ ប្រភេទដំណាំគម្របដីដែលគេធ្លាប់ដាំដុះកន្លងមកមានដូចជា៖

- ស្ទីលឡូសាំងតែស (*Stylosanthes*)
- មូគូណា (*Mucuna bracteata*)
- ពូអេរអារីយ៉ា (*Pueraria phaseoloides*)
- សង់ត្រូសេម៉ា (*Centrosema pubescens*)
- ប្រាការីយ៉ា (*Brachiaria brizantha*)
- កាឡូប៉ូយ៉ូម (*Calopogonium mucunoides*)...។




*រូបភាពទី២៖ ការដាំដំណាំគម្របដីចន្លោះរងកៅស៊ូ*

### គ. ការចិញ្ចឹមសត្វ

ការចិញ្ចឹមសត្វតាមចន្លោះរងកៅស៊ូ គឺជាមុខរបរមួយដែលកសិករកៅស៊ូគ្រួសារអាចរកប្រាក់ចំណូលបានច្រើនគួរសមទាំងក្នុងអំឡុងពេលកៅស៊ូថៃទាំ និងកៅស៊ូចៀរជ័រ។ មុខរបរចិញ្ចឹមសត្វក្នុងចម្ការកៅស៊ូដែលកសិករគួរពិចារណាមានដូចខាងក្រោម៖

- ការចិញ្ចឹមឃ្មុំ
- ការចិញ្ចឹមកង្កែប និង
- ការចិញ្ចឹមមាន់។







*រូបភាពទី៣៖ ការចិញ្ចឹមឃ្មុំ កង្កែប និងមាន់ក្នុងចម្ការកៅស៊ូ*